**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
***Nation - Religion - King***

**ក្រសួងពាណិជ្ជកម្ម**
*Ministry of Commerce*
លេខ ០៤៧៦ ព.ណ.ក.ស.ម

ភ្នំពេញ, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៥

## <u>ជម្រាបមក</u>

## លោកនាយកក្រុមហ៊ុន ម៉ាកឃ៍ ឡែធីង ខូ អិលធីឌី

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកអំពូលភ្លើង និងកុងតាក់ម៉ាក CDN西顿 ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **ម៉ាកឃ៍ ឡែធីង ខូ អិលធីឌី** ។

**យោង:** - មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **ម៉ាកឃ៍ ឡែធីង ខូ អិលធីឌី** ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន HUIZHOU CDN INDUSTRIAL DEVELOPMENT CO., LTD ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក CDN西顿 លេខចុះបញ្ជី KH/៥១២៩០/១៤ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកនាយកថា ក្រសួងពាណិជ្ជកម្ម ឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកអំពូលភ្លើង និងកុងតាក់ម៉ាក CDN西顿 ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **ម៉ាកឃ៍ ឡែធីង ខូ អិលធីឌី** ដែលទទួលបានពីក្រុមហ៊ុន HUIZHOU CDN INDUSTRIAL DEVELOPMENT CO., LTD ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ម្ចាស់ម៉ាក ដែលក្រសួងបានតម្កល់ទុករួចហើយ ។

លិខិតទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកនេះ មានសុពលភាពត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ គិតចាប់ពីក្រោយថ្ងៃចុះហត្ថលេខាចំនួន ៩០(កៅសិប) ថ្ងៃ ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិវិញ មុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន HUIZHOU CDN INDUSTRIAL DEVELOPMENT CO., LTD ដែលជាម្ចាស់ម៉ាក CDN西顿 នេះ ។

នីតិបុគ្គលដែលទទួលបានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកនៃផលិតផលម៉ាក CDN西顿 នេះ ត្រូវបោះពុម្ពផ្សាយលិខិតទទួលស្គាល់នេះក្នុងទំព័រខាងមុខរបស់សារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានច្បាប់ និងសារាចរណែនាំរបស់រាជរដ្ឋាភិបាលទាក់ទងនឹងការគ្រប់គ្រងសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ។

អាស្រ័យហេតុនេះ សូមលោកនាយកក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក-ប្រជា**

<u>ចម្លងជូន:</u>
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **គាត ឈន់**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារ
- ឯកសារ - កាលប្បវត្តិ

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA* *Phone/Facsimile: (855)-23 866 469*